គ.ជ.ប

# ព្រឹត្តិបត្រ

## គោលនយោបាយរបស់គណបក្សនយោបាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ចេញផ្សាយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ លេខ ១

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# នីតិកាលទី៧ ឆ្នាំ២០២៣

ថ្ងៃបោះឆ្នោត ៖ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរសព្ទ (Tel) : (+855) 23 235 271

អ៊ីម៉ែល(Email): info@nec.gov.kh

Website: www.nec.gov.kh, voterlist.nec.gov.kh

Facebook/Youtube: National Election Committee

APP: NEC KH

គ.ជ.ប

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

## ការគូសសញ្ញាគាំទ្រគណបក្សលើសន្លឹកឆ្នោត

**១** លោកអ្នកត្រូវគូសសញ្ញាណាមួយ ដូចខាងក្រោម៖

✓ ឬ X ឬ + ឬ – ឬ / ឬ \ ឬ V ឬ U ឬ ∩ ឬ 0

( ឬ ) ឬ ~ ជាដើម ឬគូសសញ្ញាណាដែលគេមិនអាចស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត

**២** សន្លឹកឆ្នោតដែលមិនអាចយកជាការបាន មានដូចជា៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតជាដើម

**៣** គ.ជ.ប សូមលើកទឹកចិត្តឱ្យគូសសញ្ញាដូចខាងក្រោម៖

✓

# មាតិកា

ទំព័រ


• គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ........................................ ១
• គណបក្សបំណងពលរដ្ឋ ........................................ ២
• គណបក្សស្ត្រីដើម្បីស្ត្រី ........................................ ៣
• គណបក្សខ្មែរឈប់ក្រ ........................................ ៤
• គណបក្សប្រជាជនកម្ពុជា ........................................ ៥
• គណបក្សសញ្ជាតិកម្ពុជា ........................................ ៦
• គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ........................................ ៧
• គណបក្សខ្មែររួបរួមជាតិ ........................................ ៨
• គណបក្សធម្មាធិបតេយ្យ ........................................ ៩
• គណបក្សខ្មែរតែមួយ ........................................ ១០
• គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ........................................ ១១
• គណបក្សកសិករ ........................................ ១២
• គណបក្សឯកភាពជាតិខ្មែរ ........................................ ១៣
• គណបក្សកម្លាំងប្រជាធិបតេយ្យ ........................................ ១៤
• គណបក្សយុវជនកម្ពុជា ........................................ ១៥
• គណបក្សហ្វ៊ុនស៊ិនប៉ិច ........................................ ១៦
• គណបក្សខ្មែរអភិរក្ស ........................................ ១៧
• ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ................ ១៨
• សេចក្តីអំពាវនាវ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ........ ១៩
• សេចក្តីអំពាវនាវ ស្តីពីការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ............. ២០

# គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ

**សាមគ្គីភាព ភាតរភាព វិវឌ្ឍនភាព**

## គោលការណ៍នយោបាយ

គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យមានទិសដៅអភិវឌ្ឍប្រទេសជាតិ ដោយផ្អែកទៅលើគោលការណ៍ប្រជាធិបតេយ្យ សេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី ។ យើងខ្ញុំប្រកាន់យកជំហរលើចំណុចចំនួន៣ រួមក្នុងសមីការ ៖ សាមគ្គីភាព + ភាតរភាព = សន្តិភាព សន្តិភាព => វិវឌ្ឍភាព ដោយដាក់ចុះនូវវិធានការធំៗ ដូចតទៅ ៖

១–កែលម្អកិច្ចប្រតិបត្តិលទ្ធិប្រជាធិបតេយ្យដោយបង្កលក្ខណៈឲ្យការបែងចែកបានដាច់ស្រេចពីគ្នា អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

២–កែទម្រង់ប្រព័ន្ធតុលាការឲ្យមានភាពឯករាជ ៖ ការជ្រើសតាំងប្រធានសាលាដំបូងប្រចាំខេត្តនីមួយៗតាមរយៈការបោះឆ្នោតជាសកលដោយប្រជាពលរដ្ឋសម្រាប់២ឆ្នាំម្តង ។

៣–តម្លាភាព និងយុត្តិធម៌សង្គម
–បន្តឹងការត្រួតពិនិត្យ និងពង្រឹងការប្រមូលពន្ធដារ ។
–រាល់ការដេញថ្លៃរបស់រដ្ឋ ត្រូវប្រព្រឹត្តទៅជាសាធារណៈ និងផ្សាយបន្តផ្ទាល់លើកញ្ចក់ទូរទស្សន៍ជាតិ ។
–ជៀសវាងមិនឲ្យមន្ត្រីនៃក្រសួងសាមីដែលមានទំនាស់ជាមួយប្រជាពលរដ្ឋចូលរួមក្នុងគណៈកម្មការដោះស្រាយវិវាទ ។

៤–សន្តិសុខសង្គម
–លាតសន្ធឹងជាលក្ខណៈសកលនូវការធានារ៉ាប់រងផ្នែកសុខាភិបាលដល់ពលករ–និយោជិតក្នុងគ្រប់វិស័យ ។
–កំណត់ប្រាក់បៀវត្សរ៍អប្បបរិមាទៅគ្រប់វិស័យការងារ ។
–បន្តផ្តល់សាច់ប្រាក់ដល់ក្រុមជនក្រីក្រ និងងាយរងគ្រោះ។
–រដ្ឋទទួលបន្ទុកតម្រូវការព្យាបាលសម្រាប់ជនជរា ជនពិការ ស្ត្រីឯកោមានផ្ទៃពោះ និងកុមារកំព្រា ។

៥–វិស័យសុខាភិបាល
–កាត់បន្ថយរយៈចម្ងាយពីទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋទៅដល់មជ្ឈមណ្ឌលសុខភាព និងការរង់ចាំ ។
–បង្កើនបុគ្គលិកសុខាភិបាលយ៉ាងតិច១០០០នាក់ក្នុង១ឆ្នាំ

៦–វិស័យកសិកម្ម និងសន្តិសុខស្បៀងអាហារ
–កែទម្រង់ដីធ្លីដោយកំណត់ច្បាស់លាស់អំពីផ្ទៃដីសម្រាប់ការដាំដុះ និងតំបន់ដីធ្លីលំនៅដ្ឋាន ។
–បង្កើតកសិដ្ឋានពហុវិស័យគំរូគ្រប់គ្រងដោយជំនាញរបស់ក្រសួងកសិកម្ម និងកសិដ្ឋានសហគមន៍តាមជនបទឆ្ងាយ ។

៧–វិស័យជលផល និងព្រៃឈើ
–លុបបំបាត់ចោលភូមិឃុំបណ្តែតទឹកទាំងអស់ ។
–បង្កើនទម្ងន់ទោសបទល្មើសជលផល និងបទល្មើសព្រៃឲ្យស្មើនឹងបទល្មើសគ្រឿងញៀន ។

៨–វិស័យឧស្សាហកម្ម
បង្កលក្ខណៈអំណោយផលដល់ការវិនិយោគពហុវិស័យលើផ្នែកឧស្សាហកម្មផលិតកម្ម ។

៩–វិស័យអប់រំ ៖
–បន្ថែមម៉ោងមេរៀនគណិតវិទ្យា និងភាសាបរទេស ។
–កែទម្រង់ទិសដៅនៃការសិក្សាឆ្ពោះទៅរកវិស័យឌីហ្ស៊ីថល និងបច្ចេកវិទ្យាឈានមុខ ។

១០–នយោបាយក្រៅប្រទេស និងសហប្រតិបត្តិការអន្តរជាតិ៖
–គោរពតាមខ្លឹមសារ និងស្មារតីនៃមាត្រា១របស់ច្បាប់រដ្ឋធម្មនុញ្ញ ។
–គោរព និងអនុវត្តតាមសន្ធិសញ្ញាអន្តរជាតិទាំងឡាយដែលកម្ពុជាជាហត្ថលេខី ។

១១–វិស័យការពារជាតិ
–កំណត់យកទម្រង់កងយោធពលខេមរភូមិន្ទជាកងទ័ពវិជ្ជាជីវៈសកម្ម អមជាជំនួយដោយទាហានកំណែន។
–ផ្លាស់ប្តូរទ្រឹស្តីយោធាពីចម្បាំងតម្រាបុរាណទៅជាកងទ័ពទំនើប ដោយប្រើប្រាស់បច្ចេកវិទ្យាឈានមុខ ។
–ពង្រាងនយោបាយកម្មវិធីទំនើបកម្មឧបករណ៍–សម្ភារទ័ព ។

# គណបក្សបំណងពលរដ្ឋ

## PEOPLE PURPOSE PARTY

**ដោយយើង របស់យើង ដើម្បីជាតិយើង**

## គោលនយោបាយ

១. កសាងមាតុភូមិមួយដែលពលរដ្ឋមានភាពជាម្ចាស់ រស់ដោយសេចក្តីថ្លៃថ្នូរ ប្រកាន់ខ្ជាប់នូវស្មារតីចូលរួម **ដោយយើង របស់យើង ដើម្បីជាតិយើង** ។

២. លើកកម្ពស់សិទ្ធិជាម្ចាស់ប្រទេសរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដើម្បីក្លាយជាសក្តានុពល សម្រាប់កសាងប្រទេសជាតិឲ្យមានសេរីភាព យុត្តិធម៌ សន្តិភាព និងវិបុលភាពជាតិ។

៣. ប្រកាន់ខ្ជាប់គោលការណ៍ប្រជាធិបតេយ្យ អនុវត្តប្រព័ន្ធការងារសមូហភាពសម្រេចបុគ្គលទទួលខុសត្រូវអនុវត្ត និងធានាជីវភាពរស់នៅប្រជាពលរដ្ឋគ្រប់រូបបានសម្បូររុងរឿងថ្លៃថ្នូរក្នុងមិត្តភាព ភាតរភាព និងភក្តីភាព ដែលធានាបានភាពស្មើមុខមាត់ជាមួយបណ្តាប្រទេសលើពិភពលោក។

៤. ការកសាងសង្គមកម្ពុជាលើកកម្ពស់កម្មវិធីអភិវឌ្ឍចំណេះដឹងទូលំទូលាយដល់ពលរដ្ឋទូទៅពិសេសវិស័យបច្ចេកវិទ្យានិងវិស័យសុខមាលភាពសង្គមដោយគ្មានការរើសអើង។

៥. បណ្តុះគំនិតដល់ពលរដ្ឋគ្រប់រូបឈរលើសកម្មភាពក្នុងស្មារតីទទួលខុសត្រូវដោយខ្លួន យើងនិងក្នុងផ្ទត់គំនិតមាតុភូមិរបស់យើងអ្វីៗដើម្បីជាតិយើង។ ការបណ្តុះផ្ទត់គំនិតនេះ នឹង បញ្ចូលក្នុងកម្មវិធីសិក្សាលើវិស័យអប់រំចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា។

៦. លើកទឹកចិត្តដល់យុវជនបញ្ញវន្តក្នុងនិងក្រៅប្រទេស ចូលរួមអភិវឌ្ឍប្រទេសដោយស្មើភាព គ្មានការរើសអើង។

៧. រក្សានិងទំនាក់ទំនងល្អជាមួយបណ្តាប្រទេសនិងបណ្តាប្រជាជាតិលើសាកលលោក តាមគោលការណ៍សមភាពនិងគោរពប្រយោជន៍គ្នាទៅវិញទៅមក។

៨. សហប្រតិបត្តិការជាមួយគណបក្សដទៃ ដោយឈរលើស្មារតីផលប្រយោជន៍ជាតិរួមនិងមិនរើសអើងដោយទស្សនៈនយោបាយនិងសាសនាផ្សេងគ្នា។

៩. បណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍប្រទេសទៅតាមមេរៀនរបស់ព្រះសម្មាសម្ពុទ្ធ៖ **មជ្ឈិមប្បដិបទា** ផ្លូវកណ្តាល ,**អប្បមាទេន សម្បាទេថ** មិនប្រមាទ ,**សព្វបាបស្ស អករណំ** លុបបំបាត់ចោលនូវរាល់សេចក្តីអាក្រក់ **កុសលស្ស ឧបសម្បទា** បំពេញនូវរាល់សេចក្តីល្អ និងសចិត្ត**បរិយោទបនំ** លាងជម្រះចិត្តសន្តានឱ្យភ្លឺស្វាង។

**១២** ☑ **គណបក្ស បំណងពលរដ្ឋ**
**គ.ប.ព**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណបក្សស្ត្រីដើម្បីស្ត្រី

លេខ ០៤..............

## គោលនយោបាយរបស់គណបក្សស្ត្រីដើម្បីស្ត្រី

១ ការពារនិងលើកតម្កើងស្ត្រីជាចម្បង

២ ការពារអតីតនាយករដ្ឋមន្ត្រីនិងមិនសើរើរចនាសម្ព័ន្ធចាស់របស់នាយករដ្ឋមន្ត្រី

៣ រក្សាការពាររចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលចាស់ នឹងកែតម្រូវបន្ថែមនៅចំណុចខ្វះខាត

៤ ជួយចិញ្ចឹមចាស់ជរានិងក្មេងកំព្រាទូទាំងប្រទេសដោយផ្តល់កន្លែងស្នាក់នៅនិងផ្តល់អាហារគ្រប់គ្រាន់ ដល់ពួកគាត់ មានអ្នកមើលថែនិងមានពេទ្យព្យាបាលដោយមិនគិតថ្លៃ។

៥ កាត់បន្ថយគ្រឿងស្រវឹង និងការផ្សព្វផ្សាយដែលនាំអោយប៉ះពាល់សុខភាពដល់សាធារណៈ

៦ លុបបំបាត់គ្រឿងញៀន និង លុបបំបាត់អំពើពុករលួយ

៧ ជួយផ្តល់លទ្ធភាពដល់អ្នកទោសឲ្យរស់រានស្មើភាពក្នុងនាមជាមនុស្សជាតិ

៨ ជួយដោះបំណុលដល់ចាស់ជរាដែលក្រីក្រខ្លាំង

៩បង្កើតផ្សារផលិតផលកសិកម្ម សិប្បកម្ម ឧស្សាហកម្មនៅក្នុងស្រុក។ (គោលនយោបាយភូមិមួយផ្សារមួយ)

១០ លុបបំបាត់ល្បែងស៊ីសងតាមសហគមន៍

១១ បង្រួបបង្រួមជាតិសាសន៍ខ្មែរទូទាំងពិភពលោកដើម្បីរួមគ្នាជួយដល់សេដ្ឋកិច្ចជាតិខ្មែរ ឲ្យរីកចម្រើនរុងរឿង។

ពាក្យស្លោក(ស្ត្រីអាចធ្វើបាន)

ថ្ងៃ ចន្ទ ២រោច ខែជេស្ឋ ឆ្នាំថោះបញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ត្រូវនិងថ្ងៃទី៥ ខែ មិថុនា ឆ្នាំ ២០២៣

**ប្រធានគណបក្សស្ត្រីដើម្បីស្ត្រី**

WOMEN'S PARTY FOR WOMEN

**ស៊ុំ សុធី**

# គោលនយោបាយ និងយុទ្ធសាស្ត្រ ១២ចំណុច របស់គណបក្សខ្មែរឈប់ក្រ៖

**I- ផ្តល់សេវាកម្មផ្នែកសុខភាពតាមបែបបទបស្ចឹមប្រទេសសហរដ្ឋអាមេរិក**

១- ផ្តល់ប្រាក់ឧបត្ថម្ភនិងប័ណ្ណទិញម្ហូបប្រចាំខែ និងប័ណ្ណធានារ៉ាប់រងដើម្បីថៃទាំព្យាបាលសុខភាពដោយវេជ្ជបណ្ឌិតមាន បច្ចេកទេសនិងទេពកោសល្យកំរិតខ្ពស់មកពីបរទេសជូនដល់ជនក្រីក្រ, ចាស់ជរា, ជនពិការ, កុមារ, ស្ត្រីមានផ្ទៃពោះដោយឥតគិតថ្លៃ។ សូមបញ្ជាក់អោយច្បាស់ថា យើងនឹងផ្តល់អោយខ្មែរទូទៅនូវប័ណ្ណធានារ៉ាប់រងសុខភាព ទាំងអស់សំរាប់ទៅព្យាបាលជម្ងឺ។

២-ផ្តល់ផ្ទះសម្បែងដីធ្លីជាកម្មសិទ្ធិដែលមិនអាចជនណារំលោភបំពានបាន ជូនដល់ជនក្រីក្រគ្មានលំនៅ ទីជំរក។

៣-បង្កើតមណ្ឌលថៃរក្សា ស្នាក់នៅ ព្យាបាល ជូនដល់ជនដែលគ្មានគ្រួសារ ញាតិមិត្តបងប្អូនជាទីពឹងពាក់ និងអ្នកមានប្រាក់ចំណូលតិច។

៤-សំរាប់និវត្តន៍ជនគឺផ្តល់ការឧបត្ថម្ភដូចលេខរៀងខាងលើ(ទី១+ទី២+៣) ព្រមទាំងដំឡើងបៀវត្ស និងចេញថ្លៃអោយទៅធ្វើទស្សនកិច្ចនៅបរទេស នេះជាការលើកទឹកចិត្ត។

៥-ផ្តល់និងជួយរកការងារដល់ជនពិការទៅតាមមុខជំនាញ

៦-ផ្ទង់ស្មារតីដើម្បីកាត់បន្ថយមរណភាពនៃស្ត្រីមានផ្ទៃពោះស្លាប់ដោយផ្តល់ជំនួយពិសេស សំរាប់ការសំរាលទារក

**II-បង្កើតនិងរកការងារដើម្បីបង្កើនសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋ ជាពិសេស កម្មករ កសិករ អាជីវករ**

១-បង្កើត និងរកការងារដល់ប្រជាពលរដ្ឋអោយមានប្រាក់ចំណូលកំរឹតខ្ពស់មានជីវភាពធូរធារ

២-កម្មករដែលធ្វើការតាមរោងចក្រ ម្ចាស់ក្រុមហ៊ុនត្រូវតែទទួលខុសត្រូវ :

- ការធានារ៉ាប់រងផ្នែកសុខភាព ប្រាក់ផ្តល់អោយសំរាប់វិស្សមកាល ប្រាក់ផ្តល់អោយនៅពេលចូលនិវត្តន៍
- ការធ្វើការមាន៨ម៉ោងក្នុងមួយថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ហើយសំរាកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ តែបើថែមម៉ោងគឺថែមលុយ។

៣-បែងចែកដីដែលមានជីវជាតិជូនកសិករសំរាប់ធ្វើស្រែចម្ការមាន ស្រូវ ជាពិសេសដាំដើមកាការ កាហ្វេ ខ្ទឹមខ្មៅ សម្រាប់ព្យាបាលរោគ និងសម្រាប់ជាតម្រូវការរបស់ពិភពលោកខ្លាំង។

ការដាំដើមកាការក្នុងរយៈពេលតែពីរទៅបីឆ្នាំប៉ុណ្ណោះនឹងអាចចាប់បេះផ្លែបានរាល់ថ្ងៃហើយមានប្រាក់ចំណូលក្នុង១ហិកតា គឺបាន៦០០០ដុល្លារ ក្នុងមួយឆ្នាំគិតជាមធ្យម ហើយដើមកាការនេះ ត្រូវរស់មានអាយុសង្ឃ័យពី៥០ទៅ៦០ឆ្នាំទៀតផង។

៤-នាំអ្នកបច្ចេកទេសមកបង្រៀនអោយចេះធ្វើជីរ ចេះថៃទាំដំណាំនិងធ្វើកសិ-ឧស្សាហកម្មដូចជាផ្លែឈើ ត្រូវផ្អែទៅជាកញ្ចប់ និងដាក់កំប៉ុងជាដើម ។ល។

៥-យើងនឹងនាំវិនិយោគិនល្អៗមកពីបស្ចឹមប្រទេសមកជួយអភិវឌ្ឍន៍ ដូចជាសហរដ្ឋអាមេរិក-សហភាពអឺរ៉ុប ជាដើម។

៦-វិនិយោគិនត្រូវអោយចំណេញទាំងម្ចាស់ក្រុមហ៊ុនទាំងរដ្ឋាភិបាលនិងកម្មករ មិនត្រូវក្ស័យទុន រត់ចោលរោងចក្រឡើយ។

៧- ម្ចាស់ក្រុមហ៊ុនមិនត្រូវប្រើអំណាចជិះជាន់រំលោ ភបំពានអារម្មណ៍និងរាងកាយឬប្រកាន់ពូជសាសន៍ដាច់ខាត។

**III- បំបាត់អំពើពុករលួយ បង្កើនការការពារសុវត្ថិភាព-សន្តិភាព និងស្ថិរភាព ជូនប្រជាពលរដ្ឋ**

១-តំឡើងប្រាក់បៀវត្សជូនកម្មករ រាជការ ទាំងទាហាន ប៉ូលីស សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកធ្វើការគ្រប់ជាន់ថ្នាក់ដោយមិនមានប្រកាន់និន្នាការនយោបាយណាទាំងអស់ ដើម្បីអោយមានការផ្លាស់ប្តូរជីវិតថ្មី។

២-សើរើ និងយកកម្មវិធីបំបាត់ភាពក្រីក្ររបស់អន្តរជាតិ UN, US, EU, Bill gates, Jr. (Sustainable Development Goals = SDG) យកមកអនុវត្តន៍អោយខ្មែរ និងពិភពលោកឈប់ក្រអោយបានក្នុងកំឡុងឆ្នាំ២០៣០។

៣-បង្កើតប្រព័ន្ធអេឡិចត្រូនិចនៃការបំបាត់អំពើពុករលួយពីថ្នាក់លើដល់ថ្នាក់ក្រោម។ ឧក្រឹដ្ឋជនត្រូវទទួលទោស ។ ប្រព័ន្ធនេះបានអនុវត្តន៍នៅទឹកដីសហរដ្ឋអាមេរិកបានជោគជ័យ ។

៤- ជួយដោះស្រាយសងជំនួសប្រជាពលរដ្ឋក្រីក្រខ្មែរណាដែលជំពាក់បំណុលធនាគារពុំអាចមានលទ្ធភាពសងបាន។

៥- យក Build Back Better “B3” ផែនការពិភពលោកអោយល្អប្រសើរជាងមុន ។ សួរថាតើផែនការពិភពលោកដែលល្អប្រសើរជាងមុនមានន័យយ៉ាងណាខ្លះ ? គឺស្វែងរកការដោះស្រាយអោយប្រទេសកំពុងអភិវឌ្ឍន៍ (ប្រទេសក្រីក្រ=Developing Countries) អោយក្លាយជាប្រទេសអភិវឌ្ឍន៍ (Developed Countries) ដែលមានចំនួន ៤០ ពាន់ពាន់លានដុល្លារ ($40 Trilion) អោយបានសម្រេចក្នុងឆ្នាំ ២០៣៥ និងបំបាត់ការបញ្ចេញជាតិកាបូន ជាតិពុល កាត់បន្ថយបរិស្ថាន និងកំដៅផែនដីអោយអស់សូន្យត្រឹមឆ្នាំ ២០៥០។

**IV- បញ្ឈប់ការរំលោភបំពានកម្មសិទ្ធិដីធ្លីនិងការកាប់រំលាយព្រៃឈើ:**

១-បញ្ឈប់ឧក្រឹដ្ឋជនចោរប្លន់យកដីធ្លីជារបស់ប្រជាពលរដ្ឋ និងបញ្ឈប់ជនកាប់រំលាយព្រៃឈើ និងពួកឈ្មួញទិញព្រៃឈើ។

២-បង្កើតច្បាប់ថ្មីមួយតម្រូវអោយប្រជារាស្ត្រម្នាក់ត្រូវទទួលខុសត្រូវដាំ និងថៃរក្សាដើមឈើ២ដើម ចាប់ពីអាយុ៩ឆ្នាំឡើងទៅ។

៣-ដាក់ទណ្ឌកម្មចំពោះជនណាដែលបំផ្លាញព្រៃឈើ ដេញប្រជាពលរដ្ឋចេញពីដីធ្លី និងបំពុលបរិស្ថាន។

**V- រៀបចំប្រទេសអោយក្លាយជាប្រទេសបៃតង-ចូលរួមកាត់បន្ថយកំដៅផែនដី :**

១-ដាំដើមឈើឡើងវិញនៅគ្រប់ទីភូមិស្ថាន មានដើមត្នោត ដើមឈើមានផ្លែ និងឈើមានតំលៃ ដូចជា ក្រញូង បេង នាងនួន ។ល។ ជនកាប់ឈើ១ដើមត្រូវអោយដាំដើមឈើ ៥០០ ដើមជំនួសវិញ។

២- ចែកដីអោយប្រជាពលរដ្ឋក្រីក្រ ដើម្បីអោយមានដីធ្វើស្រែ និងចំការ សំរាប់កែប្រែជីវិតថ្មី។

៣- បង្កើតភ្នាក់ងារពិសេសអោយមានអំណាចអាច ការពារនិងរក្សាព្រៃឈើនិងសត្វព្រៃ សត្វស្រុក មច្ឆាជាតិ អោយបាន។

៤- ដាក់ទោសជនប្រព្រឹត្តបទល្មើសទាំងអស់ជាកំហឹត បើទោះជាសញ្ជាតិណាក៏ដោយ។

៥- ជីកប្រឡាយ និងបង្កើតចរាចរផ្លូវទឹក ដើម្បីយកទឹកពីប្រភពទន្លេ មកស្រោចស្រពដំណាំពេញទូទាំងប្រទេសខ្មែរ។

**VI- អភិវឌ្ឍន៍វិស័យសិក្សាធិការនិងបណ្តុះបណ្តាលកីឡាជាតិ និងអន្តរជាតិដាក់ក្នុងកម្មវិធីសិក្សា :**

១- ផ្តល់សេវាកម្មដឹកជញ្ជូនសិស្ស និស្សិតពីផ្ទះទៅសាលារៀន និងផ្តល់អាហារថ្ងៃត្រង់ពីថ្នាក់បឋមសិក្សាដល់ថ្នាក់ទី ១២។

## គណបក្សប្រជាជនកម្ពុជា ការពារ និងលើកស្ទួយ ផលប្រយោជន៍របស់ប្រជាជន

១- ថែរក្សា ការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ដើម្បីធានាភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិ។

២- ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព ងាយស្រួល និងជឿទុកចិត្ត, បន្តអនុវត្តការមិនយកកម្រៃសេវាលើការចុះបញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព ការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

៣- បន្តមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ ជួយកសិករក្នុងការពង្រីកផលិតកម្ម និងការរកទីផ្សារលក់កសិផលដោយថ្លៃសមរម្យ, បែងចែកដី និងផ្តល់កម្មសិទ្ធិដីជូនគ្រួសារក្រីក្រគ្មានដីដែលបានអនុវត្តតាមលក្ខខណ្ឌសម្បទានដីសង្គមកិច្ច, ទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីគ្រប់ប្រភេទរបស់រដ្ឋដោយខុសច្បាប់ និងបន្តធ្វើប្រទានកម្មដីជូនប្រជាជនរស់នៅ និងអាស្រ័យផលលើទីតាំងដីរដ្ឋតាមគោលការណ៍ដែលរដ្ឋបានកំណត់។

៤- បន្តអនុវត្តគោលការណ៍លុបការបង់ភាស៊ី និងការបង់ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង កញ្ជើ ល្អី នៅតាមទីផ្សារនានានៅទូទាំងប្រទេស, អាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋមានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើតូប ពាន ស្តង់លក់ដូរ និងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះឱ្យកូនចៅ ឬអ្នកដទៃបាន, បន្តកាត់បន្ថយចំណាយសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈយន្តការនៃការរក្សាស្ថិរភាពថ្លៃម្ហូបអាហារ និងកាត់បន្ថយថ្លៃទឹក និងថ្លៃអគ្គិសនីសម្រាប់ប្រជាជនទូទៅ។

៥- លើកកម្ពស់ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព, បន្តអភិវឌ្ឍគ្រប់ឃុំ សង្កាត់ ឱ្យមានផ្លូវគមនាគមន៍កាន់តែល្អ តាមរយៈការជួសជុលថែទាំផ្លូវជាប្រចាំ ការស្ថាបនាផ្លូវថ្មីៗថែមទៀត និងការលើកកម្ពស់ផ្លូវពីផ្លូវដីទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង, មានអគ្គិសនី និងទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់, មានប្រព័ន្ធធារាសាស្ត្រកាន់តែប្រសើរឡើង និងមានសេវាទូរគមនាគមន៍ប្រកបដោយគុណភាព។

៦- បន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, បន្តកែសម្រួល និងដំឡើងប្រាក់សោធននិវត្តន៍របស់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, បន្តដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិតព្រមទាំងរក្សាអត្ថប្រយោជន៍ផ្សេងៗសម្រាប់កម្មករ និយោជិត, បន្តអនុវត្តគោលការណ៍មិនយកពន្ធលើប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ និងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិត, លើកកម្ពស់ការការពារសិទ្ធិ និងផលប្រយោជន៍កម្មករទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ, បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងបន្តអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ និងកម្មវិធីឧបត្ថម្ភកម្មការិនីមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំ។

៧- លើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងសមធម៌ជូនប្រជាជន។ បន្តផ្តល់សេវាថែទាំសុខភាពបឋមនៅមណ្ឌលសុខភាព និងសេវាបង្ការ ធ្វើរោគវិនិច្ឆ័យ ព្យាបាល ថែទាំ និងស្តារនីតិសម្បទានៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយមិនបង់ថ្លៃជូនប្រជាជនក្រីក្រ និងងាយរងគ្រោះ តាមរយៈកម្មវិធីមូលនិធិសមធម៌សុខាភិបាល, ពង្រីកសាលាបឋមសិក្សាដល់គ្រប់ភូមិ ពង្រីកអនុវិទ្យាល័យដល់គ្រប់ឃុំ និងបង្កើនវិទ្យាល័យនៅតាមស្រុក, យុវជនទទួលបានឱកាសក្នុងការរៀនសូត្រ បណ្តុះបណ្តាលវិជ្ជាជីវៈ និងមានការងារធ្វើ។

៨- ពង្រឹងការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍តាមច្បាប់ជាធរមាន លើកកម្ពស់ការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបការលួចជ្រៀតចូល ការស្នាក់នៅ និងការធ្វើសកម្មភាពខុសច្បាប់របស់ជនបរទេសដែលបានចូលមកកម្ពុជា។

| | | |
|---|---|---|
| ១៨ | ✓ | គណបក្សប្រជាជនកម្ពុជា<br>ប្រ.ជ |

**គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ឥប្រជាជនកម្ពុជា ជាអ្នកឈ្នះ!**



# គោលនយោបាយ
# គណបក្សសញ្ជាតិកម្ពុជា

## គណបក្សសញ្ជាតិកម្ពុជា

## លោកឪ លោកតាមហាឪ
## ព្រះរស់ព្រហ្មបួនអសង្ខេយ្យ

**គណបក្សសញ្ជាតិកម្ពុជា** មានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យ មានសញ្ញាព្រះអាទិត្យ និងព្រះចន្ទជួបគ្នា មានលំដាប់លេខរៀងទី៣ក្នុងសន្លឹកឆ្នោត។

ព្រះអាទិត្យ និងព្រះចន្ទជួបគ្នាតំណាងឲ្យការរួបរួមគ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឲ្យតែអ្នកទាំងអស់នោះត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិ និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះអាទិត្យពណ៌មាស និងព្រះចន្ទពណ៌ប្រាក់តំណាងឲ្យលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើង រុងរឿង។

**គណបក្សសញ្ជាតិកម្ពុជា** មានគោលនយោបាយជាសច្ចភាពចំនួន៤ខ គឺសាមគ្គីធម៌ប្រជាជាតិ ធ្វើបុណ្យរក្សាសីល និងបណ្តុះគ្រាប់ពូជព្រះនិព្វាន ដែលជាគោលនយោបាយបង្កើតអោយមានសុខសន្តិភាពនិងការអភិវឌ្ឍ ។

**គណបក្សសញ្ជាតិកម្ពុជា** ជាស្នាព្រះហស្តដ៏ថ្លៃថ្លារបស់លោកឪ លោកតាមហាឪ ព្រះរស់ព្រហ្មបួនអសង្ខេយ្យ។ ព្រះអង្គជាព្រះប្រធានចលនាតស៊ូផ្ទៃក្នុងប្រឆាំងនឹងបរទេសឈ្លានពានតាំងពីទសវត្សរ៍ឆ្នាំ១៩៨០ និងជាព្រះប្រធានស្ថាប-និកនៃគណបក្សសញ្ជាតិកម្ពុជា ព្រះអង្គតែងតែរួមសុខរួមទុក្ខ ជាមួយប្រជារាស្ត្ររបស់ព្រះអង្គគ្រប់កាលៈទេសៈ។

បានកសាងសមិទ្ធិផលព្រះពុទ្ធសាសនាជាច្រើនដូចជា៖ ព្រះពុទ្ធរូបព្រះភ្នែន៥,៥០ម៉ែត្រ ធ្វើអំពីថ្មតាន់សុទ្ធ និងព្រះសក្យមុនីចេតីយ៍តម្កល់ព្រះបរមសិរីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ នៅក្នុងវត្តព្រះរាជនិវេសនដ្ឋានស្រីសរឈរ ហៅវត្តស៊ីធរអតីតរាជធានីទួលបាសានខេត្តកណ្តាល វត្តកបិលមហាព្រហ្មនិម្មិតនៅលើកំពូលភ្នំខ្មោលឪរ៉ាល់ខេត្តកំពង់ស្ពឺ វត្តមហាទេវៈមហាទីរីពើងព្រះ ពុទ្ធលើកំពូលភ្នំត្បែងមានជ័យ ប្រាសាទធព្វ័ណ្ណរង្សីសម្រាប់តម្កល់ទុកព្រះរូបអតីតបច្ចុប្បន្ននិងអនាគត ប្រាសាទបុទមបញ្ចភទកប្ប ព្រះចន្ទឆាយ៉ាតម្កល់ព្រះពុទ្ធរូបព្រះភ្នែន៦ម៉ែត្រធ្វើអំពីថ្មខៀវតាន់សុទ្ធពីស្រុកគូលេន និងកំពុងកសាងប្រាសាទអចិន្តេយ្យគុណ ប្រាសាទព្រះមហាម្កុដត្រៃលោកា ប្រាសាទវេទយន្តតម្កល់ទុកអាណាចក្រព្រហ្មភ្នំរាប ខេត្តព្រះវិហារ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ បងប្អូនជនរួមសញ្ជាតិខ្មែរទាំងអស់ជាទីគោរពស្រឡាញ់រាប់អាន គណបក្សសញ្ជាតិកម្ពុជាជានិច្ចកាលប្រកាន់ខ្ជាប់នូវគោលការណ៍ ការពារ រួមសុខរួមទុក្ខស្និទ្ធស្នាល ស្រោចស្រង់បម្រើ និងឧបត្ថម្ភប្រជារាស្ត្រ។

សូមបោះឆ្នោតជូនគណបក្សសញ្ជាតិកម្ពុជា ដែលមាននិមិត្តសញ្ញាព្រះអាទិត្យ និងព្រះចន្ទជួបគ្នាដែលមានលំដាប់លេខរៀងទី៣ក្នុងសន្លឹងឆ្នោត គឺអ្នកឈ្នះក៏សុខ អ្នកចាញ់ក៏សុខ ហើយអ្នកដែលមានសេចក្តីសុខបំផុត គឺប្រជានៃសញ្ជាតិខ្មែរគឺសុខទាំងអស់គ្នាដើម្បីរួមបន្តរួមចំណែកការពារសុខសន្តិភាព និងការអភិវឌ្ឍជូនជាតិមាតុភូមិ។

# គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចបង្កើតឡើងដើម្បីអ្វី ?

**គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច**បង្កើតឡើងក្នុងគោលបំណងតែមួយគឺ បង្កើតគំនិតពិតពីបេះដូងរួមគ្នា ដើម្បីធ្វើការអភិវឌ្ឍន៍ខ្លួន និងសង្គម គឺមានន័យថា ខ្មែរ + អភិវឌ្ឍន៍ = សេដ្ឋកិច្ច ក៏ជាអត្ថន័យដ៏ធំធេងមួយដែលបង្ហាញយ៉ាងច្បាស់ មនុស្សគ្រប់រូប បើមានឆន្ទះហើយតែគ្មានសកម្មភាពក៏អត់ន័យនោះដែរ ទើបគណបក្សយើងសម្រេចដាក់ឈ្មោះនេះ ដែលមានន័យថា មានឆន្ទះ មានសកម្មភាព នោះនឹងមានលទ្ធផល ពោលគឺ ខ្មែរ+អភិវឌ្ឍន៍ = សេដ្ឋកិច្ច សរុបមកវិញ គឺខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច។

**និមិត្តសញ្ញារបស់គណបក្ស**

រូបទំពាំង ០៥ ដើម

រូបទំពាំងខ្ពស់ជាងដើមឫស្សី មានន័យថា:

- យុវវ័យបច្ចុប្បន្ន ស្នងមនុស្សជំនាន់មុន ។

- ទំពាំង៥ដើមបញ្ជាក់ថា យុវវ័យបច្ចុប្បន្ន គឺជាយុវជនជំនាន់អង្គរធំ ។

- មនុស្សជំនាន់អង្គរ គឺៈ សញ្ញាប្រាសាទកំពូល៥ ។

- ទំពាំង ៥ ដើម គឺៈ ប្រាសាទកំពូល ៥ ក្នុងសាសនា ព្រះពុទ្ធ ៥ អង្គ ។

- ក្នុងអាណត្តិទី០៥ ឈរនៅលើខ្សែរៀងទី៥ ។

**គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** មានគោលនយោបាយធំៗ ចំនួន៥ គឺៈ

**១/ អភិវឌ្ឍវិស័យធនធានមនុស្ស**

**២/ អភិវឌ្ឍន៍កសិឧស្សាហកម្មៈ**

**៣/ អភិវឌ្ឍវិស័យទេសចរណ៍ៈ**

**៤/ គោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចជាតិ**

**៥/ អភិវឌ្ឍន៍ដំណើរការប្រព័ន្ធយុត្តិធម៌**

ពុកម៉ែបងប្អូនជាទីគោរព តើកម្ពុជាមានធន ធានមនុស្សដែរឬទេ? បាទគឺប្រាកដណាស់ ពិតជាមាន ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាកំពុងរងនូវការខាតបង់ធនធានមនុស្ស យ៉ាងខ្លាំង ក៏ព្រោះតែការកង្វះខាត នៃទីផ្សារ ការងារជូនពួកគាត់ ការមិនមានទីផ្សារការ ងារគ្រប់គ្រាន់នេះ ពលរដ្ឋយ៉ាងច្រើនត្រូវ បាននាំគ្នាចំណាកស្រុកធ្វើការក្រៅប្រទេស ចំណែកពលរដ្ឋជាច្រើននៅ ក្នុងស្រុកក៏ត្រូវបានបាត់បង់ការងារ ក៏ព្រោះ តែប្រព័ន្ធបច្ចេកវិទ្យាមានច្រើនជាងការប្រើ កម្លាំងមនុស្ស មនុស្សមួយចំនួនបានសម្រេចចិត្តបង្កប់នូវធនធានទេពកោសលរបស់ខ្លួន ប្តូរមកវិញ ការរត់ម៉ូតូឌុប ការរត់កង់៣ ការធ្វើជាកម្មករ ក្នុងបំណងធ្វើការដោះបញ្ហាមួយគ្រា ហើយ អ្នកខ្លះ ក៏អាចធ្វើរហូតហួសវ័យអាយុរបស់ ខ្លួន ក្លាយជាហេតុផលធ្វើឲ្យលែងខ្វល់ខ្វាយពីសង្គម ។

ពុកម៉ែបងប្អូនជាទីគោរព ដើម្បីជួយអោយគោលនយោបាយ របស់គណបក្សយើងខ្ញុំអាច មានឱកាសបម្រើបង ប្អូនបាន សូមកុំភ្លេចជួយគាំទ្រ និង បោះឆ្នោតជូន គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច មានលេខរៀងទី១៣ នៃ សន្លឹកឆ្នោត ដែលមាននិមិត្តសញ្ញា រូបទំពាំងស្នង ឫស្សី ៕



## គណបក្សខ្មែររួបរួមជាតិ

**រាជរដ្ឋាភិបាលរួបរួមជាតិ ដឹកនាំដោយ ខ.រ.ជ**
**បង្កើនចំណូលរដ្ឋ បន្ថយចំណាយរដ្ឋ ៖**

បង្កើនចំណូលរដ្ឋបានពី ១,៥០០ ទៅ២,០០០លានដុល្លារ បន្ថែមលើចំណូលជាតិបច្ចុប្បន្នដែលជាប្រភពចំណូលក្នុងស្រុករួមមាន៖

១. បង្កើននូវប្រសិទ្ធភាពការប្រមូលពន្ធដារ និងពន្ធគយ

២. បង្កើននូវប្រសិទ្ធភាព ការប្រមូលប្រាក់ពីទេសចរណ៍

៣. យកឈ្នួលដីសម្បទានសេដ្ឋកិច្ច ក្នុងតម្លៃយ៉ាងតិច ១០០ ដុល្លារ ក្នុងមួយហិកតាក្នុងមួយឆ្នាំ

៤. ការផ្តល់អាជ្ញាប័ណ្ណ និងការធ្វើអាជីវកម្មរ៉ែផ្សេងៗ ជាពិសេសចំណូលពីរ៉ែមាស ត្បូងថ្ម ប្រេងកាត និងឧស្ម័ន

៥. ធ្វើច្បាប់គ្រប់គ្រងបនល្បែង កាស៊ីណូ និងការកំណត់ពន្ធច្បាស់

៦. កាត់បន្ថយនូវការចំណាយអត់ប្រយោជន៍ដូចជា "មន្ត្រីខ្មោច" និងសមាជិករដ្ឋាភិបាល (ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ) អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ អភិបាលរង រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ

៧. កាត់បន្ថយក្រសួង អាជ្ញាធរជាតិ ស្ថាប័នមួយចំនួនដោយកែសម្រួល ដាក់បញ្ចូលគ្នា(១៨ក្រសួងយ៉ាងច្រើន)

៨. លុបបំបាត់ បោសសម្អាតអំពើពុករលួយ ពីលើចុះក្រោម

៩. លទ្ធកម្មហ្មត់ចត់ច្បាស់លាស់ លុបបំបាត់ការបំប៉ោងចំណាយក្នុងការសាងសង់ និងការទិញសម្ភារៈសម្រាប់រដ្ឋ ដោយគ្មានការដេញថ្លៃ និងត្រួតពិនិត្យត្រឹមត្រូវ

១០. ម្ចាស់ដីដែលមិនបង្កបង្កើនផល មានទំហំលើសពី ១០ ហិកតា ត្រូវបង់ពន្ធចូលរដ្ឋ

១១. ផ្តល់មធ្យោបាយដល់ថ្នាក់ក្រោមជាតិ ១០%នៃថវិកាជាតិ (យ៉ាងតិច ៥០ម៉ឺនដុល្លារ ក្នុង១ឃុំ-សង្កាត់ ក្នុង១ឆ្នាំ)

@@@@@@@

## សេចក្តីប្រកាស

**គណបក្សខ្មែររួបរួមជាតិ** ប្តេជ្ញាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងអត្តសញ្ញាណជាតិ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យគង់វង្ស។ ពង្រឹងឯកភាពជាតិ និងបង្រួបបង្រួមជាតិខ្មែរទាំងមូល តាមរយៈការគោរពសិទ្ធិមនុស្ស ពង្រឹងនីតិរដ្ឋ ប្រជាធិបតេយ្យសេរី ពហុបក្ស ដោយគោរពរដ្ឋធម្មនុញ្ញ និងកិច្ចព្រមព្រៀងសន្តិភាព ស្តីពី កម្ពុជា នៅទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

**រាជរដ្ឋាភិបាលរួបរួមជាតិ ដឹកនាំដោយ ខ.រ.ជ ៖**

១. ធានាសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស ដើម្បីប្រជាពលរដ្ឋ

២.យុត្តិធម៌សង្គម នីតិរដ្ឋ សិទ្ធិសេរីភាព ការគោរពសិទ្ធិមនុស្ស

៣. ប្រជាពលរដ្ឋជាម្ចាស់កសាងរដ្ឋទំនើប សង្គមស៊ីវិល័យថ្លៃថ្នូរ

៤. អភិវឌ្ឍន៍ប្រកបដោយចីរភាព និងជីវភាពពលរដ្ឋធូរធារ

៥. ប្រជាធិបតេយ្យសេរី កណ្តាលនិយម សន្តិសហវិជ្ជមាន

- លុបបំបាត់អំពើពុករលួយ ដែលនាំឱ្យមានអយុត្តិធម៌សង្គម
- តុលាការ និងសេវាសាធារណៈ ស្អាតស្អំ យុត្តិធម៌ មិនពុករលួយ
- កម្មករប្រាក់ខែគោលយ៉ាងតិច ១លានរៀល ក្នុង១ខែ
- ចាស់ៗពីអាយុ៦៥ឆ្នាំឡើងទទួលបានយ៉ាងតិច ១០ម៉ឺនរៀល ក្នុង១ខែ
- ពលរដ្ឋខ្មែរ ព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋ បង់ថ្លៃ១ម៉ឺនរៀល
- តម្លៃស្រូវទាបបំផុត ១.២០០៛/Kg - ធានាទីផ្សារ និងតម្លៃកសិផល (កសិកម្ម៖បញ្ចុះតម្លៃប្រេង ជីកសិកម្ម និងការប្រាក់ ៣% ក្នុង១ឆ្នាំ)
- គ្រូបង្រៀនប្រាក់ខែគោលយ៉ាងតិច ២លានរៀល ក្នុង១ខែ មានគុណភាព បង្រៀនពេញថ្ងៃ និងបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសនៅតាមពន្ធនាគារ
- ភូមិឃុំ មានសុខសុវត្ថិភាព គ្មានល្បែងស៊ីសង គ្មានគ្រឿងញៀន
- អនុវត្តច្បាប់ ស្តីពីអន្តោប្រវេសន៍ យ៉ាងតឹងរ៉ឹងបំផុត

**«ប្រជាធិបតេយ្យសេរី កណ្តាលនិយម»** គ្មានការរើសអើង (នយោបាយ ជំនឿ សាសនា)




## ខ្មែររួបរួម ខ្មែរខ្លាំង!

**គណបក្ស ធម្មាធិបតេយ្យ**
**Dharmacracy Party**
មេត្តា ករុណា មុទិតា ឧបេក្ខា



# ១០ ✓ គណបក្សធម្មាធិបតេយ្យ គ.ធ

## គោលនយោបាយ

### គណបក្សធម្មាធិបតេយ្យប្រកាន់យកនូវគោលការណ៍មាតាធិបតេយ្យ នឹងបន្តជូត ទឹកភ្នែកអយុត្តិធម៌នៅលើវង់ភ័ក្ត្ររបស់ប្រជានុរាស្ត្រខ្មែរចេញឲ្យស្អាត

១- ដោះស្រាយជម្លោះដីធ្លី និងបញ្ហាសង្គមផ្សេងៗទូទាំងប្រទេស ប្រកបដោយតម្លាភាព ត្រឹមត្រូវ និងយុត្តិធម៌។

២- បំបាត់អំពើពុករលួយឲ្យមានប្រសិទ្ធិភាពខ្ពស់។

៣- កែតម្រូវប្រព័ន្ធតុលាការឲ្យមានយុត្តិធម៌ពិតប្រាកដ។

៤- កែទម្រង់ប្រព័ន្ធកសិកម្ម និងរៀបចំប្រព័ន្ធធារាសាស្ត្រឲ្យបានត្រឹមត្រូវ ដើម្បីផ្តល់ទឹកតាមតម្រូវការរបស់ប្រជាកសិករ យកទៅស្រោចស្រពស្រែចម្ការរបស់ពួកគាត់ និងកាត់បន្ថយទឹកជំនន់តាមខេត្ត/ក្រុង ទូទាំងប្រទេស។

៥- រកទីផ្សារសម្រាប់កសិផល និងឧស្សាហផល ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាកសិករ និងកម្មករ។

៦- កែទម្រង់ប្រព័ន្ធសុខាភិបាលឲ្យមានប្រសិទ្ធិភាពល្អប្រសើរឡើងវិញ។

៧- កែទម្រង់ប្រព័ន្ធអប់រំឲ្យល្អប្រសើរ ត្រូវមានម៉ោងសម្រាប់ព្រះសង្ឃបង្រៀនកូនសិស្សអំពីសាសនា និងគុណធម៌ ផ្តល់ប្រាក់កម្ចីគ្មានការប្រាក់សម្រាប់និស្សិត ដើម្បីជួយពួកគាត់ឲ្យបានបញ្ចប់ការសិក្សា។

៨- អ្នកនយោបាយត្រូវមានសញ្ជាតិខ្មែរតែមួយ គឺខ្មែរពីកំណើត។

ថ្ងៃពុធ ២រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣
**ប្រធានគណបក្ស**

**ពោធិគី សាវត្ថី**



លោក **គុជ លី**
ស្ថាបនិក និងជាប្រធានគណបក្ស

**បទពិសោធការងារនយោបាយ** :
-បានចាប់ផ្ដើមពីឆ្នាំ១៩៩៥ រហូតដល់បច្ចុប្បន្ន

**កម្រិតវប្បធម៌** :
-បេក្ខជនបណ្ឌិតវិទ្យាសាស្ត្រនយោបាយ
-បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលសាធារណៈ
-បរិញ្ញាបត្រនីតិសាស្ត្រ

# គណបក្សខ្មែរតែមួយ
## មានគោលនយោបាយជាអាទិភាព៨ចំណុច ក្នុងការចូលរួមបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ឆ្នាំ២០២៣

**១-ប្រព័ន្ធយុត្តិធម៌៖** " អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ " គឺត្រូវការបែងចែកអំណាចរដ្ឋទាំងបីឱ្យដាច់ពីគ្នាច្បាស់លាស់ត្រឹមត្រូវ។ ជាពិសេសអំណាចនីតិប្រតិបត្តិ កុំជ្រៀតជ្រែកកិច្ចការតុលាការជាដាច់ខាត ដើម្បីឱ្យសមាជិកសង្គមមានជំនឿជឿទុកចិត្តកាន់តែខ្លាំងឡើងលើប្រព័ន្ធតុលាការឯករាជ្យ។

**២-ព្រំដែនដីគោក៖** រដ្ឋបង្កើត " មូលនិធិព្រំដែនដីគោក " ដើម្បីកសាងរបងការពារព្រំដែនដីគោកជាមួយប្រទេសជិតខាងទាំងអស់។ រដ្ឋអាចផ្ដល់ដីតាមបណ្ដោយព្រំដែនដីគោកជូនក្រុមគ្រួសារ ទាហាន គ្រួសារប៉ូលិសសម្រាប់ធ្វើលំនៅឋានដោយឥតគិតថ្លៃ ដើម្បីឱ្យពួកគាត់រស់នៅអាស្រ័យផល និងការពារទឹកដីមាតុភូមិកម្ពុជា។

**៣-គ្រឹះស្ថានសិក្សា៖** រដ្ឋបង្កើត " សាលាមត្តេយ្យមួយ " ក្នុងមួយឃុំ និងការបង្កើតសាលាជំនាញវិជ្ជាជីវៈនៅតាមខេត្តនីមួយៗ ដើម្បី " តម្រង់ទិសយុវជនបន្តវេន "។ រដ្ឋដំឡើងប្រាក់បៀវត្ស " ២លាន រៀល " ជូនគ្រូបង្រៀនកម្រិតបឋមសិក្សានិងមធ្យមសិក្សា ដើម្បីលុបបំបាត់ចោលនូវវប្បធម៌បង្រៀនគួររកកម្រៃបន្ថែម។

**៤-គ្រឹះស្ថានសុខាភិបាល៖** ការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ គ្រូពេទ្យ និងការផ្ដល់សេវាឱ្យរហ័សទាន់ចិត្តជូនប្រជាពលរដ្ឋ ដោយគ្មានការរើសអើង និងជាពិសេសគ្រួសារក្រីក្រ និងគ្រួសារជនពិការព្យាបាលជំងឺ " ឥតបង់ថ្លៃ " នៅគ្រប់មន្ទីរពេទ្យរដ្ឋ។ រដ្ឋដំឡើងប្រាក់បៀវត្ស " ២លាន រៀល " ជូនគ្រូពេទ្យគ្រប់មន្ទីរពេទ្យរដ្ឋទាំងអស់។

**៥-វិស័យការងារ៖** រដ្ឋធានានិងដំឡើងប្រាក់ខែគោលកម្មករអប្បបរមា " ១លាន ៨សែន រៀល " ក្នុងមួយខែ និងការងារគ្រឹះស្ថានឯកជនប្រាក់ខែគោល " ២លាន រៀល " ក្នុងមួយខែ និងមន្ត្រីរាជការ " ២លាន ៦សែន រៀល " ក្នុងមួយខែ។ ក្នុងករណី ហានិភ័យការងារ គឺរដ្ឋធានាទទួលខុសត្រូវតាមរយៈបេឡាជាតិសន្តិសុខសង្គម ប.ស.ស។

**៦-វិស័យកសិកម្ម និងតម្លៃកសិផល៖** រដ្ឋបង្កើត " សភាកសិករ " ក្នុងមួយឃុំចំនួនមួយដើម្បីកំណត់តម្លៃស្រូវ អង្ករ និងផលិតផលកសិកម្មផ្សេងៗទៀត ដើម្បីកុំឱ្យឈ្មួញកណ្ដាលបង្អាប់តម្លៃតាមតែអំពើចិត្ត។

**៧-មនុស្សចាស់គ្មានទីពឹង និងជនពិការ៖** ចាប់ពីអាយុ ៦៥ឆ្នាំឡើងទៅមានការធានាថែទាំពីរដ្ឋបាលឃុំសង្កាត់ដោយមានប្រាក់ឧបត្ថម្ភក្នុងមួយនាក់ " ២៦ម៉ឺន រៀល " ក្នុងមួយខែ។

**៨-កុំលក់ដីស្រែ៖** ការបង្កើតច្បាប់ដើម្បីកំណត់ភូមិសាស្ត្រ " ការពារដីស្រែ " របស់ប្រជាពលរដ្ឋតាមខេត្តនីមួយៗ ច្បាប់នេះមានគោលបំណងហាមឃាត់ម្ចាស់បុរីនានាធ្វើអាជីវកម្ម ទិញដីស្រែបង្កើតផ្ទះល្វែងច្រើនលើសលុបអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាកសិករគ្មានដីធ្វើស្រែទៅថ្ងៃអនាគត។

២ | ✓ | **គណបក្សខ្មែរតែមួយ**
**គ.ខ.ម**

# គណបក្សប្រជាធិបតេយ្យមូលដ្ឋាន

Grassroots Democratic Party

**សាមគ្គីភាព យុត្តិធម៌ អហិង្សា**

## អំពីប្រវត្តិគណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)

នៅខែកញ្ញា ឆ្នាំ២០១៤ ក្រុមបញ្ញវន្ត និងអ្នកដឹកនាំអង្គការសង្គមស៊ីវិលខ្មែរមួយចំនួនបានបង្កើតបណ្ដាញសង្គម «ខ្មែរដើម្បីខ្មែរ» ក្នុងគោលបំណង ធ្វើការតស៊ូមតិ និងអប់រំនយោបាយដល់ប្រជាពលរដ្ឋ ជាពិសេសជំរុញគណបក្សនយោបាយនីមួយៗ មានគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងបក្ស ហើយធ្វើការប្រកួតប្រជែងគ្នានូវគោលនយោបាយល្អៗ ដើម្បីដោះស្រាយបញ្ហាប្រជាពលរដ្ឋ និងបញ្ហាជាតិ។

ចាប់ពីខែមករា ឆ្នាំ២០១៥ សមាជិកស្ថាបនិកនៃបណ្ដាញ **«ខ្មែរដើម្បីខ្មែរ»** បានពិគ្រោះយោបល់ជាមួយតំណាងប្រជាពលរដ្ឋ ជាពិសេស មកពីខេត្ត កំពង់ស្ពឺ តាកែវ និងកំពត រហូតឈានដល់បង្កើតគណបក្សនយោបាយថ្មីមួយនៅថ្ងៃទី**០២ ខែសីហា ឆ្នាំ២០១៥** ដែលមានឈ្មោះថា «**គណបក្សប្រជាធិបតេយ្យមូលដ្ឋាន**» (Grassroots Democratic Party - GDP)។ ដើម្បីផ្ដល់កិត្តិយស ក៏ដូចជាការរំឭកគុណដល់លោកបណ្ឌិត **កែម ឡី** ដែលបានចូលរួមដំណើរការបង្កើតគណបក្សប្រជាធិបតេយ្យមូលដ្ឋាន យើងបានចាត់ទុករូបគាត់ជា **«បិតាស្ថាបនិកគណបក្ស»**។

### ស្លាកសញ្ញា និងអត្ថន័យ

គបម មានស្លាកសញ្ញារូបត្រីកោណ មានផ្ទៃពណ៌បៃតង ព័ទ្ធជុំវិញដោយ ជ្រុងសងខាងពណ៌ខៀវ និងជ្រុងបាតពណ៌ក្រហមដឹតធំ មានអក្សរ គបម ពណ៌ស នៅកណ្ដាល និងមានអក្សរពណ៌ខៀវ សរសេរ ថា គណបក្សប្រជាធិបតេយ្យមូលដ្ឋាននៅពីក្រោម ។

**រូបត្រីកោណ តំណាង ប្រជាធិបតេយ្យពីក្រោមឡើងលើ ការទទួលខុសត្រូវពីលើមកក្រោម**

**១១** ✓ **គណបក្សប្រជាធិបតេយ្យមូលដ្ឋាន**
**គបម**

# គណបក្ស កសិករ

# FAMER’S PARTY

**គតបណ្ឌិត យុត្តិធម៌ សាមគ្គីភាព និងការអភិវឌ្ឍជាតិ**

## ទិសដៅ និងយុទ្ធសាស្ត្ររបស់គណបក្សកសិករសំរាប់ ២០២៣~២០២៨

១. គោរពនិងការពាររដ្ឋធម្មនុញ្ញ ។

២. ការពារឯករាជ្យ អធិបតេយ្យនិងបូរណភាពទឹកដីកម្ពុជា ។

៣. ពង្រឹងច្បាប់អន្តោប្រវេសន៍ និងប្រឆាំងការហូរចូលនូវជនអន្តោប្រវេសន៍ខុសច្បាប់មករស់នៅលើ ទឹកដីកម្ពុជា ។

៤. ពង្រឹងនីតិរដ្ឋ តុលាការឯករាជ្យ មិនស្ថិតក្រោមសម្ពាធនៃគណបក្សនយោបាយ ។

៥. ប្រឆាំងអំពើពុករលួយគ្រប់រូបភាព និងឈានដល់ការលប់បំបាត់អំពើពុករលួយនៅក្នុងប្រទេស ។

៦. កែប្រែជីវភាពកសិករ លើកទឹកចិត្តជួយបំផុសនិងជំរុញដល់ចលនាដាំដុះ និងចិញ្ចឹមសត្វគ្រប់ប្រភេទ រកទីផ្សារលក់ផលិតផលជូនកសិករ ការពារផលប្រយោជន៍ជូនកសិករ និងទាមទារយុត្តិធម៌ជូនកសិករ ។

៧. ការពារធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិ និងការពារបរិស្ថាន ទប់ស្កាត់ការលំហូរចូលនូវសារធាតុគីមីគ្រប់រូបភាព

៨. ប្រកាន់ជំហរនយោបាយអព្យាក្រិតអចិន្ត្រៃយ៍ រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសក្នុង និងក្រៅភូមិភាគអាស៊ីអគ្នេយ៍ ។

៩. មិនបំរើនយោបាយអោយពួកបរទេស មិនចងសម្ព័ន្ធយោធាជាមួយប្រទេសណាមួយ ក្នុងមហិច្ឆតាបង្កសង្គ្រាមផ្ទុយពីច្បាប់ជាតិ និងអន្តរជាតិ ។

១០. ចូលរួមពង្រឹងនឹងពង្រីករបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា និងទាមទារ អោយមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ ជាពិសេសចូលរួមពង្រឹងនិតិរដ្ឋ លើកស្ទួយយន្តការបណ្តុះបណ្តាលធនធានមនុស្ស ។

**ជយោ ! គណបក្សកសិករជ័រុងរឿង**

# គោលនយោបាយអាទិភាព ៩ ចំណុចៈ

១. លុបបំបាត់អំពើពុករលួយ ទាំងក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន

២. លុបបំបាត់ការជួញដូរគ្រឿងញៀន ការរំលោភយកដីឯកជន និងដីរដ្ឋ

៣. រកទីផ្សារកសិកម្ម ធានាតម្លៃកសិផល បន្ទាបតម្លៃជីកសិកម្ម និងប្រេងឥន្ធនៈ និងរកទីផ្សារការងារជូនពលរដ្ឋ

៤. ផ្តល់ប័ណ្ណមើលថែសុខភាពជូនពលរដ្ឋក្រីក្រ ដើម្បីបានពិនិត្យ និងព្យាបាលជម្ងឺ ដោយឥតគិតថ្លៃ ផ្តល់រថយន្តសង្គ្រោះបន្ទាន់តាមមណ្ឌលសុខភាព

៥. ពង្រឹងគុណភាពអប់រំ សិក្សា៨ម៉ោងក្នុង១ថ្ងៃ និងមិនអនុញ្ញាតឱ្យមានការបង្រៀនគួរយកប្រាក់ក្នុងសាលារដ្ឋ

៦. តម្លើងប្រាក់ខែជូនមន្ត្រីរាជការថ្នាក់មូលដ្ឋាន ទាបបំផុត ២លាន៥សែនរៀល និងកម្មករ ទាបបំផុត ១លាន៥សែនរៀល

៧. ពង្រឹងយុត្តិធម៌សង្គម ការពារអ្នកទន់ខ្សោយ និងជនក្រីក្រ ស្មើគ្នាចំពោះមុខច្បាប់ និងបង្កើតក្រុមអាជ្ញាកណ្តាល ដើម្បីដោះស្រាយទំនាស់នានា

៨. ចាស់ៗ អាយុចាប់ពី៦៥ឆ្នាំឡើងទៅ ទទួលបានប្រាក់ឧបត្ថម្ភ ៣សែនរៀល ក្នុង១ខែ និងកុមារនៃគ្រួសារក្រីក្រក្រោមអាយុ៦ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភ ៥ម៉ឺនរៀលក្នុង១ខែ

៩. អនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនូវសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណា ដែលមានផលប្រយោជន៍ដល់ជាតិមាតុភូមិ

**បោះឆ្នោតជូនគណបក្សឯកភាពជាតិខ្មែរ ដើម្បីអនុវត្តនូវគោលនយោបាយដ៏មានសារៈសំខាន់ទាំង៩ចំណុចនេះ ជូនប្រជាពលរដ្ឋ!**

**គណបក្សឯកភាពជាតិខ្មែរ**
**គ.៦.៩**

# គណបក្សកម្លាំងប្រជាធិបតេយ្យ

## DEMOCRACY POWER PARTY

## យុត្តិធម៌ សេរីភាព អភិវឌ្ឍន៍

## ប្រធានគណបក្ស លោក អ៊ុន វិសិទ្ធគុន

## បាវចនាទាំងបីដែលមានខ្លឹមសារបានផ្សាភ្ជាប់ និងគោលនយោបាយសំខាន់ៗ



**គណបក្សកម្លាំងប្រជាធិបតេយ្យ** បានសង្កេតយ៉ាងហ្មត់ចត់នូវបញ្ហាក្នុងវិស័យជាច្រើនដែលបានកើតមានក្នុងសង្គមកម្ពុជាពីអតីតកាល និងបច្ចុប្បន្នដែលបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរជួបការលំបាក ខ្វះសេរីភាព គ្មានយុត្តិធម៌ ទន្ទឹមនឹងវឌ្ឍនភាពសង្គមដែលមានស្ថិរភាពទើបធ្វើឱ្យ **គណបក្សកម្លាំងប្រជាធិបតេយ្យ** សម្រេចអនុម័តនូវគោលនយោបាយជាចម្បង នៅក្នុងសមាជពេញអង្គលើកដំបូង ដើម្បីចូលរួមដោះស្រាយបញ្ហាសេដ្ឋកិច្ចប្រជាពលរដ្ឋ កាត់បន្ថយចំណាកស្រុក និងអភិវឌ្ឍន៍ប្រទេសឱ្យទាន់សម័យបែបទំនើបកម្ម ទៅតាមគោលនយោបាយរបស់គណបក្សដែលជាយុទ្ធសាស្ត្រសម្រាប់ឈានទៅដឹកនាំរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅពេលជាប់ឆ្នោតក្នុងនីតិកាលទី៧ ឆ្នាំ២០២៣ ខាងមុខនេះដែលមាន ៩ ប្រការះ

**ប្រការ១** ពង្រឹងគុណភាពផ្នែកសុខាភិបាល និងកែសម្រួលប្រព័ន្ធសេវាកម្មបន្ថែមទៀត
**ប្រការ២** បង្កើតទីផ្សារបែបទំនើបកម្មសម្រាប់វិស័យកសិកម្ម និងឧស្សាហកម្ម
**ប្រការ៣** ពង្រឹងគុណភាពវិស័យអប់រំ និងបង្កើតធនធានមនុស្សលើគ្រប់វិស័យទាំងអស់
**ប្រការ៤** អព្យាក្រឹត្យនៃអំណាចកំពូលទាំង៣ របស់រដ្ឋ
**ប្រការ៥** អភិវឌ្ឍន៍ ថែរក្សា ការពារធនធានធម្មជាតិ
**ប្រការ៦** លុបបំបាត់អំពើពុករលួយ ហើយកសាងអំណាច និងសេរីភាពជូនពលរដ្ឋ
**ប្រការ៧** គ្រប់គ្រងឱ្យបានល្អបំផុតចំពោះប្រាក់ចំណូលរដ្ឋ បង្កើនប្រាក់ចំណូលមន្ត្រីរាជការ និងកម្មករ
**ប្រការ៨** កាត់បន្ថយភាពក្រីក្រ បង្កើតការងារឱ្យបានច្រើនដល់យុវជន ដើម្បីកាត់បន្ថយចំណាកស្រុក
**ប្រការ៩** រក្សាការពារ វប្បធម៌ អរិយធម៌ ហ៊ានលះបង់ដើម្បីបូរណភាពទឹកដី និងសន្តិសុខសង្គម

យើងសាមគ្គីគ្នាដើម្បីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឱ្យមានភាពរឹងមាំដើម្បីកសាងអំណាច និងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក្នុងការជ្រើសតាំងមេដឹកនាំដោយការពេញចិត្តដើម្បីចូលរួមកសាងជាតិមាតុភូមិឱ្យបានរីកចម្រើនរុងរឿង។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣
**ប្រធានគណបក្ស**

**អ៊ុន វិសិទ្ធគុន**

**សូមបងប្អូនប្រជាពលរដ្ឋបោះឆ្នោតជូន**
**គណបក្សកម្លាំងប្រជាធិបតេយ្យ**
**ដែលមានលេខរៀងទី៥ នៅលើសន្លឹកឆ្នោត។**

**៥** **គណបក្សកម្លាំងប្រជាធិបតេយ្យ**
**គ. ក. ប**

# គណបក្សយុវជនកម្ពុជា

## គោលនយោបាយអាទិភាព ៧ ចំណុច របស់គណបក្សយុវជនកម្ពុជា

## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ឆ្នាំ២០២៣

១. បញ្ចុះថ្លៃសាំង ជីកសិកម្ម ថ្នាំជំនួយកសិកម្ម ឱ្យលក់ថោក ដើម្បីលក់ផលកសិកម្មបានថ្លៃ ហើយនៅពេលផលកសិកម្មធ្លាក់ថ្លៃ រដ្ឋនឹងបញ្ចេញថវិកាជាតិទិញផលកសិកម្មពីកសិករ ដើម្បីកុំឱ្យបងប្អូនកសិករយើងលក់ខាតជាប់បំណុលវ័នករ

២. ប្រាក់ខែមន្ត្រីរាជការចាប់ពី ២លាន ៨០ម៉ឺន រៀលឡើងទៅ រីឯប្រាក់ខែកម្មករចាប់ពី ១លាន ៤០ម៉ឺនរៀលឡើងទៅ ចាស់ៗអាយុ៦០ឆ្នាំឡើងទៅ នឹងទទួលបានប្រាក់ឧបត្ថម្ភ ៣០ម៉ឺនរៀលរាល់ខែ និងបង្កើតមណ្ឌលថែទាំចាស់ជរាគ្មានទីពឹងទូទាំងប្រទេសកម្ពុជា

៣. ការអប់រំស្មើភាពគ្នា គ្មានរៀនគួរក្រៅពីម៉ោងរដ្ឋ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយបង្កើតការងារសម្រាប់យុវជន២លាននាក់

៤. លុបបំបាត់រាល់ការរើសអើងចំពោះអ្នកជំងឺក្រីក្រនៅតាមគ្រប់មន្ទីរពេទ្យរដ្ឋ និង ព្យាបាលដោយមិនបង់ថ្លៃសេវាព្យាបាលឡើយ

៥. លុបបំបាត់ការផ្សព្វផ្សាយគ្រឿងស្រវឹងដោយអនាធិបតេយ្យ និងបោសសម្អាតការលក់ ការប្រើប្រាស់គ្រឿងញៀនពីលើដល់ក្រោម

៦. លុបបំបាត់អំពើពុករលួយគ្រប់ទម្រង់ កែប្រែប្រព័ន្ធយុត្តិធម៌ឱ្យមានយុត្តិធម៌ស្មើភាពគ្នាចំពោះមុខច្បាប់

៧. ពិនិត្យឡើងវិញនូវការអនុវត្តច្បាប់អន្តោប្រវេសន៍លើជនអន្តោប្រវេសន៍គ្រប់ជាតិសាសន៍ ដែលកំពុងរស់នៅប្រទេសកម្ពុជាឱ្យត្រឹមត្រូវស្របតាមច្បាប់អន្តោប្រវេសន៍ ច្បាប់ស្តីពីសញ្ជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា ដើម្បីការពារប្រយោជន៍ជាតិនិងការពារអធិបតេយ្យជាតិយើង

១៦ ✓ **គណបក្សយុវជនកម្ពុជា**

**គ.យ.ក**

CAMBODIAN YOUTH PARTY

# គោលនយោបាយអាទិភាពគណបក្សហ្វ៊ុនស៊ិនប៉ិច
# សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧(២០២៣)

គណបក្ស ហ្វ៊ុនស៊ិនប៉ិច ក្រោមព្រះកិច្ចដឹកនាំ របស់ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ មានគោលនយោបាយ អាទិភាព ៩ ចំណុច ដែលជាគន្លឹះ សម្រាប់ដោះស្រាយបញ្ហាជូនប្រជារាស្ត្រ និង សង្គមជាតិ សម្រាប់អាណត្តិទី៧នេះ នៅពេលណាដែល គណបក្សហ្វ៊ុនស៊ិនប៉ិច បានទទួលការទុកចិត្តពីប្រជារាស្ត្រជាម្ចាស់ឆ្នោត។

គោលនយោបាយទាំងនេះរួមមានៈ

១. ការពារព្រះរាជបល្ល័ង្ក របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងគោរពកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ។

២. ផ្តល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជំនឿសាសនា និង លើកកម្ពស់សិទ្ធិនារី ក្នុងការចូលរួមវិស័យនយោបាយ និង អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

៣. ឈប់ឱ្យប្រជារាស្ត្រខ្មែររងទុក្ខវេទនា ដោយសារប្រព័ន្ធតុលាការ ។

៤. ដោះស្រាយបញ្ហាយុវជនអត់ការងារធ្វើ។ កម្មករប្រាក់ខែទាបបំផុត១លាន២សែនរៀល។

៥. បញ្ចុះតម្លៃជី អគ្គិសនី ប្រេងឥន្ធនៈ ឱ្យបានថោក និងការប្រាក់ទាប ។

៦. រៀបចំប្រព័ន្ធអប់រំឱ្យកាន់តែមានលក្ខណៈទំនើប ដើម្បីបង្កើតការងារឱ្យយុវជន។ បង្ក្រាប ការជួញដូរគ្រឿងញៀន និង ប្រមូលជនរងគ្រោះមកព្យាបាលដោយឥតបង់ប្រាក់ ។

៧. ពិនិត្យព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋ ជូនប្រជារាស្ត្រដោយឥតបង់ប្រាក់។

៨. ប្តេជ្ញាការពារទ្រព្យសម្បត្តិសាធារណៈ និង គ្រប់គ្រងធនធានធម្មជាតិឱ្យបានត្រឹមត្រូវ ។

៩. បង្កើតមជ្ឈមណ្ឌលថែទាំសុខភាពចាស់ជរា និងផ្តល់ប្រាក់ឧបត្ថម្ភមនុស្សចាស់ មានអាយុ៦៥ឆ្នាំឡើង ទទួលបាន២០ម៉ឺនរៀលក្នុងមួយខែ ។

សូមបោះឆ្នោតជូនគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលមានលេខរៀងទី៩

៩ គណបក្សហ្វ៊ុនស៊ិនប៉ិច


ឯកឧត្តម វៀល ខេមរិន្ទ្រ
រួមគ្នាអភិរក្ស និងអភិវឌ្ឍជាតិយើង
១៥ គណបក្សខ្មែរអភិរក្ស


គណបក្សខ្មែរអភិរក្ស
បោះឆ្នោតជូនគណបក្សខ្មែរអភិរក្សដើម្បីៈ
០១.ការពារបូរណភាពទឹកដី ( ច្បាប់អន្តោប្រវេសន៍ )
០២.លុបបំបាត់អំពើពុករលួយ ( ពីលើមកក្រោម )
០៣.លុបបំបាត់គ្រឿងញៀន ( ពីលើមកក្រោម )
០៤.លើកស្ទួយវិស័យអប់រំ ( បង្កើនធនធានមនុស្ស )
០៥.លើកស្ទួយវិស័យសុខាភិបាល ( ប័ណ្ណអត្ថិភាពសម្រាប់អ្នកក្រីក្រ )
០៦.លើកស្ទួយជីវភាពប្រជាពលរដ្ឋ (កាត់បន្ថយភាពក្រីក្រ)
០៧.គោរពសិទ្ធិម្ចាស់ឆ្នោត ( ម្ចាស់អំណាច )
រួមគ្នាអភិរក្ស និងអភិវឌ្ឍជាតិយើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**

**នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

## ផ្ញើជូន ជនរួមជាតិ ជាទីគោរពស្នេហាដ៏ជ្រាលជ្រៅបំផុត

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ។ ក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវជាឱឡារិក ជូនជនរួមជាតិអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ សូមអញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ជ្រើសរើសអ្នកដឹកនាំប្រទេសជាតិ ដើម្បីការអភិវឌ្ឍ និងការរីកចម្រើនរុងរឿងថ្កើងថ្កានលើគ្រប់វិស័យ។

ការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី ២៣ ខែ កក្កដា ឆ្នាំ ២០២៣ គឺជាការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្មើភាព និងដោយសម្ងាត់ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។ ដូចនេះ សូមកុំឱ្យមានការព្រួយបារម្ភពីការគាបសង្កត់ ការគំរាមកំហែង ឬសម្លុតពីជនណាម្នាក់ ឬគណបក្សណាមួយឱ្យសោះ។

ខ្ញុំ សូមជនរួមជាតិទាំងអស់ មេត្តាប្រើសិទ្ធិសេរីភាពបោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗ ដែលមានទំនុកចិត្តទៅលើបេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយដោយសេរី ។

សូម ជនរួមជាតិទាំងអស់ ប្រកបតែនឹងព្រះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមេត្តាទទួលនូវសេចក្តីគោរពស្នេហាដ៏ជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០០៧ គ.ជ.ប. ស៊.ឃ.វ

## សេចក្តីអំពាវនាវ

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្តើមពីម៉ោង ៧:០០ព្រឹក រហូតដល់ម៉ោង ៣:០០រសៀល។ ការបោះឆ្នោតនេះ កាន់តែខិតជិតមកដល់ហើយ ហេតុនេះ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមអំពាវនាវដូចតទៅ៖

- សូមប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២២ ទាំងអស់ ត្រៀមខ្លួន និងត្រៀមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ដើម្បីចូលរួមបោះឆ្នោត នៅថ្ងៃបោះឆ្នោតឱ្យបានគ្រប់ៗគ្នា
- សូមប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២២ ដែលបានប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ហើយមិនទាន់មាន អ.ខ ឬ អ.ខ បានអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវ សូមប្រញាប់រួសរាន់ទៅស្នើសុំ ឯ.អ ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងត្រូវបញ្ជាក់សុពលភាពដោយអាជ្ញាធរឃុំ សង្កាត់ នៃឃុំ សង្កាត់ ដែលខ្លួនត្រូវទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា។ ការចេញ ឯ.អ មានរយៈពេល ៣០ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២២ ខែមិថុនា នឹងត្រូវបញ្ចប់នៅថ្ងៃសុក្រ ទី២១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៥:៣០ នាទីល្ងាច
- ប្រធានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មេឃុំ ចៅសង្កាត់ និងមេភូមិត្រូវធ្វើការផ្សព្វផ្សាយសេចក្តីអំពាវនាវនេះឱ្យបានទូលំទូលាយ ដើម្បីជំរុញឱ្យប្រជាពលរដ្ឋមកស្នើសុំ ឯ.អ បានទាន់ពេលវេលា ដោយឥតបង់ថ្លៃ។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សង្ឃឹមយ៉ាងមុតមាំថា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមេឃុំ ចៅសង្កាត់ នឹងយកចិត្តទុកដាក់ជំរុញ និងពង្រឹងការចេញ ឯ.អ ជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។៚

ថ្ងៃសុក្រ ១៣រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៣

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ : ០០៣ គ.ជ.ប. ស.ភ.ន

# សេចក្តីអំពាវនាវ

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលមានរយៈពេល ២១ថ្ងៃ ចាប់ពីថ្ងៃទី១ ខែកក្កដា រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមអំពាវនាវដល់គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ត.រ គោរពតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រមសីលធម៌ និងគោលការណ៍នានាដែលបានកំណត់ដោយ គ.ជ.ប ដើម្បីឱ្យការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយប្រព្រឹត្តទៅដោយសន្តិវិធី អហិង្សា សន្តិសុខ និងសុវត្ថិភាព។

គ.ជ.ប សូមអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងក្នុងសកម្មភាពការងាររបស់ខ្លួន និងត្រូវសម្របសម្រួលទីកន្លែង ផ្លូវ ពេលវេលា ដើម្បីឱ្យគណបក្សនយោបាយនីមួយៗ អាចអនុវត្តកម្មវិធីឃោសនាបោះឆ្នោត និងការហែក្បួនឃោសនាបោះឆ្នោតរបស់ខ្លួនប្រព្រឹត្តទៅដោយស្មើភាពគ្នា។

គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា គ្រប់គណបក្សនយោបាយ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធនឹងចូលរួមសហការតាមការអំពាវនាវក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដោយគោរពច្បាប់ជាធរមាន ដើម្បីឱ្យការឃោសនាបោះឆ្នោតនេះ ប្រព្រឹត្តទៅដោយរលូន និងធានាបាននូវសិទ្ធិរបស់គណបក្សនយោបាយ និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ៕

ថ្ងៃចន្ទ ៩ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

គ.ជ.ប

# គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧

## ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

| | | |
|---|---|---|
| ១ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | គ.ស.ស.ប |
| ២ | គណបក្សខ្មែរតែមួយ | គ.ខ.ម |
| ៣ | គណបក្សសញ្ញាតិកម្ពុជា | គ.ស.ក |
| ៤ | គណបក្សខ្មែររួបរួមជាតិ | ខ.រ.ជ |
| ៥ | គណបក្សកម្លាំងប្រជាធិបតេយ្យ | គ.ក.ប |
| ៦ | គណបក្សកសិករ | គ.ក |
| ៧ | គណបក្សស្ត្រីដើម្បីស្ត្រី | ស.ដ.ស |
| ៨ | គណបក្សខ្មែរឈប់ក្រ | គ.ខ.ឈ.ក |
| ៩ | គណបក្សហ្វ៊ុនស៊ិនប៉ិច | រ.រ.ជ.ក.ឯ.អ.ស.ស |
| ១០ | គណបក្សធម្មាធិបតេយ្យ | គ.ធ |
| ១១ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន | គបម |
| ១២ | គណបក្សបំណងពលរដ្ឋ | គ.ប.ព |
| ១៣ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | គ.ខ.អ.ស |
| ១៤ | គណបក្សឯកភាពជាតិខ្មែរ | គ.ឯ.ជ |
| ១៥ | គណបក្សខ្មែរអភិរក្ស | គ.ខ.អ |
| ១៦ | គណបក្សយុវជនកម្ពុជា | គ.យ.ក |
| ១៧ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | គ.ជ.ប.ក |
| ១៨ | គណបក្សប្រជាជនកម្ពុជា | ប្រ.ជ |

**កំណត់សម្គាល់ ៖ នេះមិនមែនជាសន្លឹកឆ្នោតទេ**